ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកំណត់និងការបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាង ទួលព័ន្ធតាឡី បឹងស្នេហ៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការបង្កើតតំបន់ប្រើប្រាស់ច្រើនយ៉ាងទួលព័ន្ធតាឡី បឹងស្នេហ៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១ .-**

ត្រូវបានកំណត់និងបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងទូលព័ន្ធតាឡី បឹងស្នេហ៍ ដែលមានផ្ទៃដីទំហំ៣ ៥៥៧(បីពាន់ប្រាំរយហាសិបប្រាំពីរ)ហិចតា ស្ថិតនៅក្នុងភូមិសាស្ត្រក្រុងព្រៃវែង ស្រុកស្វាយអន្ទរ ស្រុកពាមរក៍ និងស្រុកបាភ្នំ ខេត្តព្រៃវែង ជាពីរតំបន់គ្រប់គ្រង ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ១ និងនិយាមកា(Datum: WGS1984) ភ្ជាប់ក្នុងឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ។

**មាត្រា២ .-**

ការកំណត់និងការបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងទូលព័ន្ធតាឡី បឹងស្នេហ៍ មានគោលបំណងដូចតទៅ៖

- ធានាប្រសិទ្ធភាពនិងប្រសិទ្ធផលនៃការគ្រប់គ្រងតំបន់ប្រើប្រាស់ច្រើនយ៉ាងទូលព័ន្ធតាឡី បឹងស្នេហ៍
- ធានាការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋានក៏ដូចជាសាធារណជនក្នុងការរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះនិងធនធានធម្មជាតិក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងទូលព័ន្ធតាឡី បឹងស្នេហ៍។

**មាត្រា៣ .-**

ត្រូវបានបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងទូលព័ន្ធតាឡី បឹងស្នេហ៍ ស្ថិតនៅភូមិសាស្ត្រខេត្តព្រៃវែងជា២(ពីរ)តំបន់រួមមាន តំបន់ស្នូលនិងតំបន់ប្រើប្រាស់ដោយចីរភាព សម្រាប់បម្រើដល់ការងារគ្រប់គ្រង ថែរក្សា អភិរក្ស និងអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយនិរន្តរភាព។

**១.តំបន់ស្នូល** មានចំនួន១(មួយ)ទីតាំង មានផ្ទៃដីសរុបទំហំ៨៦(ប៉ែតសិបប្រាំមួយ)ហិចតា ស្ថិតនៅភូមិសាស្ត្រស្រុកបាភ្នំនិងស្រុកស្វាយអន្ទរ ខេត្តព្រៃវែង ដែលមាននិយាមកាគោលក្នុងឧបសម្ព័ន្ធ២។ តំបន់ស្នូលត្រូវគ្រប់គ្រងដោយក្រសួងបរិស្ថាននិងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិតាមការចាំបាច់។

**២.តំបន់ប្រើប្រាស់ដោយចីរភាព** មានចំនួន១(មួយ)ទីតាំង មានផ្ទៃដីសរុបទំហំ៣ ៤៧១(បីពាន់បួនរយចិតសិបមួយ)ហិចតា ស្ថិតនៅភូមិសាស្ត្រក្រុងព្រៃវែង ស្រុកស្វាយអន្ទរ ស្រុកពាមរក៍ និងស្រុកបាភ្នំ ខេត្តព្រៃវែង ដែលមាននិយាមកាគោលក្នុងឧបសម្ព័ន្ធ២។ តំបន់ប្រើប្រាស់ដោយចីរភាពត្រូវគ្រប់គ្រងដោយក្រសួង ស្ថាប័នពាក់ព័ន្ធតាមសមត្ថកិច្ចនិងជំនាញរៀងៗខ្លួន ដោយគោរពតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិនិងបទប្បញ្ញត្តិជាធរមាន។

**មាត្រា៤ .-**

តំបន់គ្រប់គ្រងនីមួយៗក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងទូលព័ន្ធតាឡី បឹងស្នេហ៍ អាចត្រូវបានធ្វើការកែប្រែក្នុងករណីចាំបាច់ដោយយោងតាមការសិក្សាស្រាវជ្រាវលើធនធានធម្មជាតិនិងតាមតម្រូវការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**មាត្រា៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តព្រៃវែង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៨ រោច ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ១នៃអនុក្រឹត្យលេខ..................អនក្រ.បក ចុះថ្ងៃទី..............ខែ..............ឆ្នាំ២០២១

## ផែនទីការកំណត់និងការបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងទួលពន្លៃតាឡី បឹងស្នេហ៍ ស្ថិតក្នុងភូមិសាស្ត្រខេត្តព្រៃវែង



## ឧបសម្ព័ន្ធ២នៃអនុក្រឹត្យលេខ :..១៧.......អនក្រ.បក ចុះ ថ្ងៃទី....៥.....ខែ..កុម្ភៈ...ឆ្នាំ២០២១

### ក. និយាមការគោលតំបន់ស្នូល

| X | Y | X | Y | X | Y |
|---|---|---|---|---|---|
| ៥៤៤១២០ | ១២៥៩៨៦៤ | ៥៤២៤៧៥ | ១២៦០៧៧៥ | ៥៤៣៤០២ | ១២៦១១៦៧ |
| ៥៤៣៩២៨ | ១២៥៩៧៧៥ | ៥៤២៣៩៦ | ១២៦០៨២២ | ៥៤៣៤៦៤ | ១២៦០៩១៥ |
| ៥៤៣៦៧១ | ១២៥៩៨១០ | ៥៤២៣៨៧ | ១២៦០៩០៤ | ៥៤៣៤៨៩ | ១២៦០៧៤៣ |
| ៥៤៣៦៤១ | ១២៥៩៩៤១ | ៥៤២៤៧៨ | ១២៦១០០៦ | ៥៤៣៦៨៧ | ១២៦០៤១៦ |
| ៥៤៣៥៥៨ | ១២៦០០៨៥ | ៥៤២៥៧៧ | ១២៦១១៥១ | ៥៤៤២៦៤ | ១២៦០០០៨ |
| ៥៤៣៣៩៣ | ១២៦០៤៤២ | ៥៤២៦៧៦ | ១២៦១២២៥ | ៥៤៣៩៥៨ | ១២៦០២២៣ |
| ៥៤៣២៦០ | ១២៦០៦៥០ | ៥៤២៩០២ | ១២៦១៣៥៨ | ៥៤៤០៨៧ | ១២៥៩៧៩១ |
| ៥៤២៩៤៦ | ១២៦០៨៨០ | ៥៤៣០០៩ | ១២៦១៤១១ | ៥៤៤១២០ | ១២៥៩៨៦៤ |
| ៥៤២៧៦៣ | ១២៦១០៣៦ | ៥៤៣១៩៥ | ១២៦១៤៣៦ | | |
| ៥៤២៦១៣ | ១២៦០៨៦៦ | ៥៤៣៣២១ | ១២៦១៣៣៦ | | |

### ខ. និយាមការគោលតំបន់ប្រើប្រាស់ដោយចីរភាព

| X | Y | X | Y | X | Y |
|---|---|---|---|---|---|
| ៥៤៤១៤១ | ១២៧២៧៩៣ | ៥៤៣៩២៨ | ១២៥៩៧៧៥ | ៥៤៦០២៨ | ១២៦៤៥៨២ |
| ៥៤៤០០៩ | ១២៧២៩៩១ | ៥៤៣៦៧១ | ១២៥៩៨១០ | ៥៤៥៩៥៣ | ១២៦៤៣៤៤ |
| ៥៤៣៦១៤ | ១២៧២៦៦០ | ៥៤៣៦៤១ | ១២៥៩៩៤១ | ៥៤៥០៤៧ | ១២៦៤២៦៣ |
| ៥៤៣២១៦ | ១២៧២៨៩១ | ៥៤៣៥៥៨ | ១២៦០០៨៥ | ៥៤៤២៣៥ | ១២៦៤៤៩៦ |
| ៥៤៣១៧៣ | ១២៧២៤៥៧ | ៥៤៣៣៩៣ | ១២៦០៤៤២ | ៥៤៣៧៤៤ | ១២៦៤៦០៨ |
| ៥៤៣១៤៦ | ១២៧២០៤០ | ៥៤៣២៦០ | ១២៦០៦៥០ | ៥៤៤១៣៦ | ១២៦៤៩២៤ |
| ៥៤២៧៣២ | ១២៧១៧៦៣ | ៥៤២៩៤៦ | ១២៦០៨៨០ | ៥៤៤៣៥៧ | ១២៦៤៩៨៣ |
| ៥៤២៩៨២ | ១២៧១៧២៣ | ៥៤២៧៦៣ | ១២៦១០៣៦ | ៥៤៤៣៩៩ | ១២៦៥៦៧៥ |
| ៥៤៣១៣៦ | ១២៧១៤៦៣ | ៥៤២៦១៣ | ១២៦០៨៦៦ | ៥៤៤៣៨៣ | ១២៦៦១២០ |
| ៥៤៣២៦២ | ១២៧១១៣០ | ៥៤២៤៧៥ | ១២៦០៧៧៥ | ៥៤៤២២៣ | ១២៦៦៤៣២ |
| ៥៤៣៦៨២ | ១២៧០៨៣០ | ៥៤២៣៩៦ | ១២៦០៨២២ | ៥៤៣៩២០ | ១២៦៦៥៨០ |
| ៥៤៣៧២៧ | ១២៧០៥៣០ | ៥៤២៣៨៧ | ១២៦០៩០៤ | ៥៤៣៦៨៦ | ១២៦៧០៧៣ |
| ៥៤៣៣២៤ | ១២៧០២៦៩ | ៥៤២៤៧៨ | ១២៦១០០៦ | ៥៤៤០០១ | ១២៦៧៦៩១ |
| ៥៤៣១៨៨ | ១២៦៩៧៩៣ | ៥៤២៥៧៧ | ១២៦១១៥១ | ៥៤៣៨៥០ | ១២៦៨០៦១ |
| ៥៤២៦១២ | ១២៦៩៦៦២ | ៥៤២៦៧៦ | ១២៦១២២៥ | ៥៤៣៩៣៧ | ១២៦៨៥២៧ |
| ៥៤២៣១៦ | ១២៦៩៧៥៤ | ៥៤២៩០២ | ១២៦១៣៥៨ | ៥៤៣៦៨២ | ១២៦៨៨៣៧ |
| ៥៤១៨០៨ | ១២៦៩១២៦ | ៥៤៣០០៩ | ១២៦១៤១១ | ៥៤៣៤៦៨ | ១២៦៨៧៨៦ |
| ៥៤០៧២១ | ១២៦៨៩១៦ | ៥៤៣១៩៥ | ១២៦១៤៣៦ | ៥៤៣៥៥៣ | ១២៦៨៥៤៨ |
| ៥៤០៨៥១ | ១២៦៧៩៧៧ | ៥៤៣៣២១ | ១២៦១៣៣៦ | ៥៤៣១៦២ | ១២៦៨៣៧៥ |
| ៥៤១២២៥ | ១២៦៧៩៨៤ | ៥៤៣៤០២ | ១២៦១១៦៧ | ៥៤៣១៩០ | ១២៦៨១៤០ |
| ៥៤១៥៩៨ | ១២៦៧០០០ | ៥៤៣៤៦៤ | ១២៦០៩១៥ | ៥៤២២២៧ | ១២៦៨១៩៦ |
| ៥៤១៨០៩ | ១២៦៦៧៥៦ | ៥៤៣៤៨៩ | ១២៦០៧៤៣ | ៥៤២២៧៥ | ១២៦៨១៩៦ |
| ៥៤២២៣១ | ១២៦៦២៥៨ | ៥៤៣៦៨៧ | ១២៦០៤១៦ | ៥៤៣១៥០ | ១២៦៩១៧៤ |
| ៥៤២២៩៦ | ១២៦៥៨៣៤ | ៥៤៤២៦៤ | ១២៦០០០៨ | ៥៤៣២៩៥ | ១២៦៩៥៩៥ |
| ៥៤១៧៥៩ | ១២៦៤៥៦៦ | ៥៤៣៩៥៨ | ១២៦០២២៣ | ៥៤៣៤០២ | ១២៦៩២៨១ |
| ៥៤២០១១ | ១២៦៤១៩៦ | ៥៤៤០៨៧ | ១២៥៩៧៩១ | ៥៤៣៩១៨ | ១២៦៩៣៩៣ |
| ៥៤១៨៨៨ | ១២៦៣៣១៥ | ៥៤៤១២០ | ១២៥៩៨៦៤ | ៥៤៣៦៤០ | ១២៦៩៥៤០ |

| | | | | | |
|---|---|---|---|---|---|
| ៥៤១៩០៩ | ១២៦២៧៨២ | ៥៤៤៤៤៤ | ១២៥៩៨៩៧ | ៥៤៣៧៦៥ | ១២៧០០៣៨ |
| ៥៤១៧៩៤ | ១២៦១៩២៩ | ៥៤៥៣៥២ | ១២៥៩៤៩៦ | ៥៤៣៩០០ | ១២៧០២៣៧ |
| ៥៤០៦៥៧ | ១២៦២០៩២ | ៥៤៦៣១៤ | ១២៥៩៣៧៣ | ៥៤៤២៩៨ | ១២៧០១២៦ |
| ៥៤០៥៥៥ | ១២៦១៦៥២ | ៥៤៦២៧២ | ១២៥៩៨០៤ | ៥៤៤៨០៦ | ១២៧០១៥៤ |
| ៥៤០៩៩៦ | ១២៦១៦០៥ | ៥៤៦៩០៤ | ១២៥៩៩១៧ | ៥៤៥១៣៥ | ១២៧០២៥០ |
| ៥៤០៨១៣ | ១២៦០៤២០ | ៥៤៧៣៩៤ | ១២៥៩៦៣២ | ៥៤៤៨៤៤ | ១២៧០៤៣៩ |
| ៥៤១៣១៨ | ១២៥៩៩៨២ | ៥៤៧៧០៩ | ១២៥៩៥៦៥ | ៥៤៤៦៥០ | ១២៧០៦០៦ |
| ៥៤១៧៨៦ | ១២៦០១៩០ | ៥៤៧៧៩៣ | ១២៦០០៥២ | ៥៤៤៨៣៩ | ១២៧០៩២៧ |
| ៥៤១៥៩០ | ១២៥៩៨០៤ | ៥៤៧៧៦១ | ១២៦០៤៣០ | ៥៤៤៦៧៤ | ១២៧១០៨៩ |
| ៥៤១០៧៦ | ១២៥៩២១០ | ៥៤៧៨៩២ | ១២៦០៧៤៩ | ៥៤៤២៧២ | ១២៧០៨៨៣ |
| ៥៤១២៦២ | ១២៥៨៩៦៤ | ៥៤៧២៨២ | ១២៦០៥៧៨ | ៥៤៤៤៤៧ | ១២៧០៣៨២ |
| ៥៤០៦២៨ | ១២៥៩១១៣ | ៥៤៦៧៨៨ | ១២៦០៣៦៣ | ៥៤៤១១១ | ១២៧០៤៥១ |
| ៥៤១១៧៨ | ១២៥៨៤៥២ | ៥៤៥៨៨១ | ១២៦០៥៤៤ | ៥៤៤០៨២ | ១២៧០៧៥៦ |
| ៥៤១៦៨៩ | ១២៥៨២០២ | ៥៤៥៤៧៨ | ១២៦០៦៨៩ | ៥៤៣៨០៤ | ១២៧១១៩៧ |
| ៥៤២៨៨៧ | ១២៥៨០៤៧ | ៥៤៥៧០០ | ១២៦១៤០៧ | ៥៤៣៤៥៧ | ១២៧១១៣៨ |
| ៥៤២២៧៤ | ១២៥៨៣៧៥ | ៥៤៥៤១១ | ១២៦១៦៤២ | ៥៤៣៤១០ | ១២៧១៤៣៦ |
| ៥៤២៦២៨ | ១២៥៨៩៧១ | ៥៤៤៨៦៧ | ១២៦១៧៣០ | ៥៤៣៦៨១ | ១២៧១៤១៧ |
| ៥៤៣២៥៦ | ១២៥៨៩០៤ | ៥៤៤៧៣៦ | ១២៦២៥១៤ | ៥៤៣៥៥៨ | ១២៧១៦៨១ |
| ៥៤៣៥៨៣ | ១២៥៩២២៨ | ៥៤៤៤៣៥ | ១២៦២៥៧៣ | ៥៤៣២៥៣ | ១២៧១៦២៥ |
| ៥៤៣៦៣៤ | ១២៥៩៥១៦ | ៥៤៥៣៨១ | ១២៦២៦៩៦ | ៥៤៣៣៦១ | ១២៧២២៥៣ |
| ៥៤៤០៦៧ | ១២៥៩៥២៥ | ៥៤៥១០៧ | ១២៦៣៥៧៥ | ៥៤៣៩១៧ | ១២៧២៥២៦ |
| ៥៤៤១២០ | ១២៥៩៨៦៤ | ៥៤៦០៥៤ | ១២៦៤០៥៣ | | |